# ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
# WEEKLY BULLETIN

CRF 2020/029 (ថ្ងៃទី២៤ ដល់ ៣០ ខែសីហា ឆ្នាំ២០២០)

CRF 2020/029 (24 to 30 August 2020)

## សង្ខេបព័ត៌មានសំខាន់ៗអំពីវិស័យស្រូវអង្ករប្រចាំសប្តាហ៍ (Rice News Briefing)

## ក្នុងប្រទេស (In Cambodia)



### កសិករខ្វេត្រោះផ្ទួនគ្នា ទាំងទឹកជំនន់ និងរាំងស្ងួត
### Farmers suffering from twin hazards of floods, droughts

*Khmer Times: August 25, 2020*

Floods and drought are now the major problems hitting farmers and affecting the Kingdom's food security and exports after drought left much land in the Northwest dry and cracked.

Song Saran, president of the Cambodia Rice Federation (CRF), told Khmer Times that from May to August, there is severe impact from climate change to the Cambodian dry paddy season especially Sen Kro Ob and IR varieties.

He added that according to the survey by the CRF with its members to more than 100 agriculture cooperatives, it showed that 30 to 40 percent of their dry seasonal paddy was affected by drought and they have to replant the paddy. (Read more)

### ARDB នឹងសិក្សាសំណើរបស់ CRF ដែលចង់បានទុនទិញស្រូវបន្ថែម
### ARDB will study CRF request for additional rice purchase loan

*Post Khmer: August 28, 2020*

ភ្នំពេញៈ ធនាគារកសិកម្ម និងអភិវឌ្ឍន៍ជនបទ (ARDB) ដែលគ្រប់គ្រងដោយរដ្ឋនឹងសិក្សាសំណើរបស់សហព័ន្ធស្រូវអង្ករកម្ពុជា (CRF) ក្នុងការបង្កើនទុនកម្ចីពិសេសពីរដ្ឋាភិបាល ដើម្បីប្រមូលទិញស្រូវនៅរដូវប្រមូលផលខាងមុខនេះ ដែលជាវិធានការមួយដើម្បីសម្រេចបានតាមទិសដៅនាំចេញប្រមាណ ៨០០ ០០០ តោននៅឆ្នាំនេះ។

លោក សុង សារ៉ន ប្រធាន CRF បានចូលរួមប្រជុំជាមួយប្រធានធនាគារកសិកម្ម និងអភិវឌ្ឍន៍ជនបទ (ARDB) កាលពីថ្ងៃពុធ ពិភាក្សាអំពីស្ថានការបច្ចុប្បន្ននៃទីផ្សារស្រូវអង្ករ និងការប្រមូលផល ដើម្បីសិក្សាពីលទ្ធភាពនៃការផ្តល់ទុនកម្ចីពីរដ្ឋាភិបាលក្នុងរដូវកាលប្រមូលផលស្រូវខាងមុខនេះ បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា ដោយសារតែរដូវប្រមូលផលនឹងមកដល់នៅពេលខ្លីខាងមុខនេះ ទាមទារឲ្យមានការបង្កើនកម្ចីបន្ថែមទៀតដល់វិស័យស្រូវអង្ករ ដើម្បីផ្តល់លទ្ធភាពមានមូលនិធិគ្រប់គ្រាន់ដើម្បីទិញស្រូវពីកសិករ។ (Read more)





### កសិករដាំដុះស្រូវស្វែងរកជំនួយថវិកាបន្ថែម ដោយមូលហេតុការប្រែប្រួលអាកាសធាតុ
### Rice farmers seek funding, blaming change in seasons

*Khmer Times: August 28, 2020*

The Cambodia Rice Federation (CRF) has asked the Agriculture and Rural Development Bank (ARDB) to release more funds and requested an extension to the loan cycle repayments, blaming an adjustment in the harvest season.

The request was made during a meeting to discuss the current situation of the rice market and harvest in order to study the possibility of providing loans from the government.

Song Saran, president of the CRF, raised various proposals as well as some of the challenges that the private sector in the rice sector is facing. "We want the loan cycle extending up to 11 or 12 months because we want the use of loans to be more efficient to help farmers," he said. Saran said the reason to extend the loan cycle is to adjust to climate change which he said has delayed the harvesting of rice paddy this year. (Read more)

### កម្ពុជាធានាសន្តិសុខស្បៀង និងការនាំចេញអង្ករគ្រប់គ្រាន់
### Cambodia ensures food security and rice exports

*Khmer Times: August 30, 2020*

The beginning of this season's rice harvest has been slower than in 2019. This has been brought about by drought causing slower seed-planting, resulting in some farmers having to replant and harvest has now been extended into December.

Kao Thach, director-general of the Rural Development and Agriculture Bank (RDAB), said that although the drought had impacted harvests, the government still ensures food security and that rice exports will go ahead in 2020. After attending the meeting to monitor rain-fed rice cultivation, early-season rice harvests, and rice exports in 2020, Thach confirmed that as of August, the rice grown in the rainy season of the farmers has been faster in comparison to in 2019, despite the harvest being slower. The rice harvested at the beginning of this season yields an average of 4 tonnes per hectare. (Read more)



# អន្តរជាតិ ( International )

## អ្នកនាំចេញអង្ករប្តេជ្ញាផ្តល់នូវលក្ខខណ្ឌត្រឹមត្រូវដល់កសិករដាំដុះស្រូវ
## Rice exporters vows to provide decent working conditions to grower families

ប៉ាគីស្ថាន ( Pakistan )

*Daily Times: August 23, 2020*

The rice exporters vowed to promote decent working conditions and improve livelihoods of the small land holder farmers, farm labour and families of rice transplanters in the entire rice value chain amid challenging situation of Covid-19 pandemic in South Punjab.



“We trained more 150 families on Covid-19 safety measures and also provided them decent working conditions, food packets, shelter/.... (Read more)

## តម្លៃអង្ករហក់ឡើងខ្ពស់ ខណៈទឹកជំនន់បន្តកើនឡើង
## Rice prices go up with the rising floods

បង់ក្លាដេស ( Bangladesh )

*Dhaka Tribune: August 23, 2020*

Traders blame wholesalers and millers for manipulating prices, but millers deny.



The price of several varieties of rice, including Miniket, Paijam and Swarna, went up in the capital’s kitchen markets. Traders blamed wholesalers for upping prices with the excuse of countrywide floods disrupting the supply chain and causing supply shortages. But wholesalers and rice millers claimed there was... (Read more)

## រដ្ឋាភិបាលជំរុញវិធីដោះស្រាយថ្មីលើបញ្ហាអង្ករ
## Gov’t pushes for new rice substitute

ហ្វីលីពីន ( Philipines )

*Manila Standard: August 23, 2020*

With thousands of Filipinos struggling to feed their families amid the prevailing coronavirus disease 2019 (Covid-19) pandemic, the government is looking for ways to introduce a new substitute for rice to help make more parts of the country hunger-free.

Cabinet Secretary Karlo Nograles said the government is pushing for the planting of ‘adlai,’ a gluten-free grain, to ensure food security and fight against hunger and poverty.

“We will push for the planting of adlai in the Caraga region as part of the residents’ staple food and as a source of livelihood for farmers, indigenous peoples, rebel returnees as well as those located in geographically isolated and disadvantaged areas to ensure... (Read more)

## វាលស្រែជាង ១៥០០០ រ៉ៃ ( Rai ) ខូចខាតដោយសារភ្លៀងធ្លាក់ជោគជាំនៅភាគខាងជើងនៃប្រទេសថៃ
## More than 15,000 rai of rice fields damaged by heavy rains in North of Thailand

ថៃ ( Thailand )

*Pattaya Mail: August 24, 2020*

The heavy rain situation in northern areas including Nan and Phrae provinces, has damaged over 15,000 rai of rice fields.



From an analysis of COSMO – SkyMed – 1 satellite data by Geo-Informatics and Space Technology Development Agency (GISTDA), it was found that over 15,000 rai of rice fields have been affected; most of them are along the main rivers (Read more)

## វៀតណាមនាំមុខថៃ ក្លាយជាប្រទេសនាំចេញអង្ករលេខ២លើពិភពលោក
## Exceeding Thailand, Vietnam becomes world’s 2nd largest rice exporter

វៀតណាម ( Vietnam )

*Vietnam Insider: August 24, 2020*

While the exports of many farm produce items have fallen dramatically because of the epidemic, exports of rice have been high.



The Ministry of Agriculture and Rural Development (MARD) reported that in the first seven months of the year, Vietnam exported 3.9 million tons, earning $1.9 billion. Though the export volume decreased by 1.4 percent, export turnover (Read more)

## ខ្យល់មូសុងឥណ្ឌាមានចំនួន ២៤ ភាគរយលើសកម្រិតមធ្យមនៅក្នុងខែសីហា ដែលធ្វើឱ្យភ្លៀងបន្តធ្លាក់
## Indian monsoon 24% above average in August, heavy rain

ឥណ្ឌា ( India )

*Reuters: August 25, 2020*

NEW DELHI (Reuters) - Monsoon rains, which picked up pace in August, are likely to be heavy for the rest of the month, the chief of the state-run India Meteorological Department (IMD) said, potentially benefiting summer crops such as rice, corn and cotton.

After a patchy spell in the last two weeks of July, India received 24% above average rains so far in August, and the trend is likely to continue at least through this month, Mrutyunjay Mohapatra, director general of the IMD, told Reuters.

“There’s no doubt that the quantity of rains has been excellent, but the other important feature of this year’s monsoon is that the rainfall has been very well distributed across the country,” (Read more)

## បច្ចេកវិទ្យាផ្កាយរណបដើម្បីទស្សន៍ទាយពីទំហំដំណាំ
## Satellite technology to predict rice crop size in real time

វៀតណាម ( Vietnam )

*The Land: August 25, 2020*

Groundbreaking new technology is helping develop the world’s first real-time monitoring platform for rice fields globally.



The platform, named Paddy Watch, is being developed by the University of Sydney using the Google Earth platform to help realise the Zero Hunger target of the United Nations 2030 Agenda. Paddy Watch uses radar satellite images and new cloud technology to determine where rice is planted and what stage of development it is at. (Read more)

## ចំណូលនិងទិន្នផលរបស់កសិករមានភាពប្រសើរឡើង ដោយសារមូលនិធិលើកកម្ពស់ភាពប្រកួតប្រជែងស្រូវ ( RCEF )
## Rice farmer incomes, yields improve due to RCEF — study

ហ្វីលីពីន ( Philipines )

*Business World: August 25, 2020*

RICE farmers’ incomes and yields are rising as a result of programs supported by the Rice Competitiveness Enhancement Fund (RCEF), according to a survey conducted by the Philippine Rice Research Institute (PhilRice).



PhilRice surveyed more than 4,000 RCEF beneficiaries across 55 provinces who harvested an average of 4.14 metric tons (MT) per hectare. (Read more)

## តើទឹកជំនន់នឹងធ្វើឱ្យប៉ះពាល់ដល់សន្តិសុខស្បៀងរបស់ប្រទេសចិនឬទេ?
## Graphics: Will the floods impact China’s food security?

ចិន ( China )

*CGTN: August 25, 2020*

Due to COVID-19 and floods in several southern provinces, concerns over food shortage have arisen among the public. But experts and officials of the agriculture ministry have confirmed that the impact of floods in food supply are limited.



**Food supply and demand in China**

China’s crop production can meet people’s consumption demand completely. In terms of production and demand, China’s crop output reached 664 million tonnes in 2019, including (Read more)

## ប្រទេសកាមេរូន៖ អ្នកនាំចូលអង្ករទទួលការសង្ស័យលើការក្លែងបន្លំនាំចេញអង្ករបន្តទៅប្រទេសជិតខាង
## Cameroon: Rice importers suspected of fraudulently reexporting to neighboring countries

កាមេរូន ( Cameroon )

*Business in Cameroon: August 26, 2020*

In Cameroon, the national institute for statistics INS suspects rice importers of fraudulently reexporting their products to Nigeria. Indeed, in 2019, Cameroon’s rice imports surged, inexplicably affecting the country’s food products import expenditures (up by 14.9% to XAF807.5 billion).



The institute notes that the volume of rice imported by the country rose from 561,112 tons to 894,486 tons (up by 59.4%). (Read more)

### ចិនរំពឹងពីការប្រមូលផលនៅរដូវស្លឹកឈើជ្រុះមានភាពជោគជ័យ ខណៈផលិតកម្មដំណើរការល្អ

ចិន ( China )

### China expects bumper autumn harvest amid well proceeding production: official

*Xinhua net: August 26, 2020*

BEIJING, Aug. 26 (Xinhua) -- China's autumn grain production is generally guaranteed this year, according to the Ministry of Agriculture and Rural Affairs.

This year's autumn harvest currently has a certain foundation amid the pressure of the downward trend for the domestic economy, the COVID-19 outbreak and the natural disasters, Pan Wenbo, an official with the ministry, told a press conference Wednesday. (Read more)

### តម្លៃអង្ករសរបស់វៀតណាម ឡើងខ្ពស់ជាងគេបំផុតលើពិភពលោក

វៀតណាម ( Vietnam )

### Vietnamese white rice price highest in world

*SGGP: August 27, 2020*

According to the Vietnam Food Association (VFA), Vietnamese white rice price has become the highest in the world compared to its peers from India, Thailand, Pakistan and Myanmar.



Presently, Vietnam's 5 percent broken white rice was traded at US$488-$492 per ton and Vietnam's 25 percent broken white rice was sold at $463-$467 per ton. Economists said the price of Vietnamese rice has increased to the highest for (Read more)

### ទឹកជំនន់ហូរទៅបំពេញទឹកក្នុងវាលស្រែ

ថៃ ( Thailand )

### Floodwater flow to feed rice paddies

*Bangkok Post: August 27, 2020*

The Royal Irrigation Department (RID) has revealed plans to divert masses of water now flooding Sukhothai to feed rice fields in the Chao Phraya River basin.

A system of water gates in tributary canals along the Yom River and Chao Phraya River from Sukhothai to Chai Nat, where the water will enter the basin, will be put to work in the diversion plan, according to Thaweesak Thanadechopol, the RID deputy director-general. (Read more)

### យុទ្ធសាស្ត្រស្រូវអង្ករ ផ្តោតលើទិន្នផល និងប្រភេទស្រូវ

ថៃ ( Thailand )

### Rice strategy to focus on yield, variety

*Bangkok Post: August 27, 2020*

The government wants to raise the average yield of domestic paddy production to 600 kilogrammes per rai by 2024 and focus more on premium-grade grains.



Speaking on Thursday after a meeting of the working panel on rice strategy, Commerce Minister Jurin Laksanawisit said higher spending on R&D for rice seeds and variety are desperately needed to raise rice yields to 600kg per rai. (Read more)

## ព្រឹត្តិការណ៍/សកម្មភាពប្រចាំសប្តាហ៍

## Event/ Activity

### កិច្ចប្រជុំពិភាក្សាលើបច្ចុប្បន្នភាពទីផ្សារស្រូវអង្ករ និងស្ថានភាពនៃការប្រមូលផល ដើម្បីសិក្សាអំពីលទ្ធភាពនៃការផ្តល់ទុនកម្ចីពីរាជរដ្ឋាភិបាល

### Meeting to discuss the current situation of the rice market and the harvest to study the loans from the Government



នាព្រឹកថ្ងៃពុធ ៨កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ នាទីស្តីការធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម កិច្ចប្រជុំពិភាក្សាលើបច្ចុប្បន្នភាពទីផ្សារស្រូវអង្ករ និងស្ថានភាពនៃការប្រមូលផល ដើម្បីសិក្សាអំពីលទ្ធភាពនៃការផ្តល់ទុនកញ្ចប់ថវិកាកម្ចីពីរាជរដ្ឋាភិបាល ត្រូវបានរៀបចំឡើង ក្រោមអធិបតីភាព **ឯកឧត្តម កៅ ថាច** អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ហើយទទួលបានការចូលរួមពីសហព័ន្ធស្រូវអង្ករកម្ពុជា ( ស.អ.ក ) ដែលដឹកនាំដោយ **ឧកញ៉ា សុខ សារ៉ែន** ប្រធានសហព័ន្ធ រួមជាមួយនឹង **ឧកញ៉ា គឹម សាវុធ** ទីប្រឹក្សាសហព័ន្ធអនុប្រធានក្រុមប្រឹក្សាភិបាល ( ស.អ.ក ) រួមជាមួយសមាជិក ស.អ.ក ចំនួន ៦ រូប។

ឧកញ៉ាប្រធានសហព័ន្ធ រួមជាមួយនឹង ឧកញ៉ាទីប្រឹក្សាសហព័ន្ធ អនុប្រធានក្រុមប្រឹក្សាភិបាល រួមជាមួយសមាជិក ស.អ.ក បានលើកឡើងជាសំណូមពរផ្សេងៗ ក៏ដូចជាបញ្ហាប្រឈមមួយចំនួនដែលវិស័យឯកជនក្នុង វិស័យស្រូវអង្ករកំពុងជួបប្រទះ ជូនធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ជាមូលដ្ឋានដើម្បីរាយការណ៍ និងសុំមតិណែនាំពីថ្នាក់ដឹកនាំ ជាពិសេសទាក់ទងទៅនឹងកញ្ចប់ថវិកាកម្ចី និងសំណើរសុំពន្យារពេលសងត្រឡប់ប្រាក់កម្ចី។

ទាក់ទងទៅនឹងសំណើដែលសហព័ន្ធបានលើកឡើង ឯកឧត្តមអគ្គនាយកបានទទួលយកសំណើរ តែសូមលើកយកទៅសិក្សា និងស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលកម្ពុជាជាមុនសិន។ កិច្ចប្រជុំបានបញ្ចប់ទៅនៅវេលាម៉ោង១១និង៣០នាទីព្រឹក ក្រោមបរិយាកាសរីករាយ និងកក់ក្តៅ។

Click here for English Version : Meeting to discuss the current situation of the rice market and the harvest to study the loans from the Government

### កិច្ចប្រជុំចង្អៀតពីការវិវឌ្ឍនៃការនាំចេញអង្ករកម្ពុជា ក្នុងខែសីហា ឆ្នាំ២០២០ និងផលប៉ះពាល់ និងវិស័យស្រូវអង្ករនាពេលខាងមុខ

### Meeting on the development of Cambodian rice exports in August 2020 and the impact and future of the rice sector



នារសៀលថ្ងៃព្រហស្បតិ៍ ៩កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ នាស្តីការក្រសួងពាណិជ្ជកម្ម **ឧកញ៉ា សុខ សារ៉ែន** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ( ស.អ.ក ) រួមជាមួយអនុប្រធាន នឹងទីប្រឹក្សាប្រត្តិបត្តិរបស់សហព័ន្ធស្រូវអង្ករ កម្ពុជា ចំនួន ៦រូប បានចូលរួមក្នុង "កិច្ចប្រជុំចង្អៀតស្តីពីការវិវឌ្ឍនៃការនាំចេញអង្ករកម្ពុជា ក្នុងខែសីហា ឆ្នាំ២០២០ និងផលប៉ះពាល់ និងវិស័យស្រូវអង្ករនាពេលខាងមុខ" ដែលកិច្ចប្រជុំនេះ ដឹកនាំដោយ **ឯកឧត្តម ប្នួន សារះមុនី** រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម និងចូលរួមដោយ **ឯកឧត្តម ចាន់ សុខទី** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ។

កិច្ចប្រជុំចង្អៀតនេះ ត្រូវបានរៀបចំឡើងជាបន្ទាន់ តបតាមការស្នើរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលស្នើឱ្យក្រសួងពាណិជ្ជកម្ម ក្នុងនាមជាអាណាព្យាបាលរបស់សហព័ន្ធ នៅក្នុងគោលបំណងរាយការណ៍ និងពិភាក្សាពីលទ្ធភាពជួយគាំទ្រពីស្ថាប័នពាក់ព័ន្ធនៅក្នុងរាជរដ្ឋាភិបាល ដើម្បីជួយដោះស្រាយ និងដាក់ចេញនូវផែនការសកម្មភាពក្នុងការជួយជំរុញផលិតកម្មស្រូវអង្ករ និងការនាំចេញស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ របៀបវារៈចំនួន៤ ត្រូវបានលើកឡើងនៅក្នុងអង្គប្រជុំនេះ រួមមាន៖ ១.) ការបម្រែបម្រួល អាកាសធាតុ ដែលជំរុញអោយមានភាពយឺតយ៉ាវក្នុងការប្រមូលផល និងទិន្នផល ជាពិសេសប្រភេទស្រូវសែនក្រអូប ២.) ភាពយឺតយ៉ាវក្នុងការផ្តល់ទិន្នផលបានជំរុញអោយការ នាំចេញអង្ករធ្លាក់ចុះយ៉ាងគំហុក ជាពិសេសក្នុងខែសីហា ហើយនិងឈានដល់ខែកញ្ញាផងដែរ ៣.)ការព្រួយបារម្ភក្នុងរយៈពេលវែងខាងមុខលើការបម្រែបម្រួលអាកាសធាតុលើសន្តិសុខស្បៀងក្នុងស្រុក និង៤.) ឥណទានបន្ថែមសម្រាប់ទិញស្រូវពីប្រជាកសិករ និងលក្ខខណ្ឌបង្វិល។

Click here for English Version : Meeting on the development of Cambodian rice exports in August 2020 and the impact and future of the rice sector

# កិច្ចប្រជុំពិនិត្យ និងវាយតម្លៃការប្រមូលផលស្រូវដើមដៃ និងការនាំចេញអង្ករ

## Meeting to review and evaluate rice harvest and export rice





នារសៀលថ្ងៃសុក្រ ១០កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ នាស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "កិច្ចប្រជុំពិនិត្យ និងវាយតម្លៃការប្រមូលផលស្រូវដើមដៃ និងការនាំចេញអង្ករ" ត្រូវបានរៀបចំឡើង ក្រោមការដឹកនាំរបស់ **ឯកឧត្តម ជូ ឆិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារ ក្នុងក្របខណ្ឌគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការចូលរួមពីសហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) ដែលដឹកនាំដោយ **ឧកញ៉ា ចាន់ សុឃាំង** អនុប្រធានសហព័ន្ធរួមជាមួយទីប្រឹក្សាប្រតិបត្តិរបស់សហព័ន្ធចំនួន២រូប ហើយក៏មានការចូលរួមពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត នៅក្នុងវិស័យស្រូវអង្ករផងដែរ។

កិច្ចប្រជុំពិនិត្យ និងវាយតម្លៃការប្រមូលផលស្រូវដើមដៃ និងការនាំចេញអង្ករនេះ ត្រូវបានរៀបចំឡើងក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពីសំណាក់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គួរបញ្ជាក់ផងដែរថា សហព័ន្ធស្រូវអង្ករកម្ពុជាមានការព្រួយបារម្ភលើបញ្ហាមួយចំនួន ដែលសហព័ន្ធក្រោមអាណាព្យាបាលរបស់ក្រសួងពាណិជ្ជកម្ម បានរៀបចំកិច្ចប្រជុំបន្ទាន់នាទីស្តីការក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ពិភាក្សា និងឯកភាពលើសំណូមពរ ដែលបានលើកឡើងនៅក្នុងអង្គប្រជុំ ទាក់ទងនឹងបញ្ហាមួយចំនួនដែលរួមមាន ៖ ១.) បម្រែបម្រួលអាកាសធាតុ ដែលជំរុញអោយមានភាពយឺតយ៉ាវក្នុងការប្រមូលផល និងទិន្នផល ជាពិសេសប្រភេទស្រូវសែនក្រអូប ២.) ភាពយឺតយ៉ាវក្នុងការផ្តល់ទិន្នផលបានជំរុញអោយការនាំចេញអង្ករធ្លាក់ចុះយ៉ាងគំហុក ជាពិសេសក្នុងខែសីហា ហើយនិងឈានដល់ខែកញ្ញាផងដែរ ៣.) ការព្រួយបារម្ភក្នុងរយៈពេលវែងខាងមុខ លើការបម្រែបម្រួលអាកាសធាតុលើសន្តិសុខស្បៀងក្នុងស្រុក និង ៤.) ឥណទានបន្ថែមដល់រោងម៉ាស៊ីន ក្នុងការប្រមូលទិញស្រូវពីប្រជាកសិករ និងលក្ខខណ្ឌបង្វិល នារដូវកាលច្រូតកាត់ថ្មី។

បន្ទាប់ពីការពិភាក្សា ផ្លាស់ប្តូរយោបល់ យ៉ាងផុសផុលពីសំណាក់សមាជិកអង្គប្រជុំ និងក្រោមការសម្របសម្រួលរបស់ឯកឧត្តមប្រធានអង្គប្រជុំរួចមក ឯកឧត្តមប្រធានបានធ្វើការវាយតម្លៃខ្ពស់ចំពោះធាតុចូលទាំងអស់ ហើយឯកឧត្តមនឹងរាយការណ៍ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យបន្ត ដើម្បីសុំគោលការណ៍ដោះស្រាយ និងលើកបន្តជូនដល់ប្រមុខរាជរដ្ឋាភិបាល ក្នុងការផ្តល់នូវសេចក្តីសម្រេច ក៏ដូចជាផ្តល់នូវអនុសាសន៍ នៅក្នុងបញ្ហានានា ដែលពាក់ព័ន្ធនឹងវិស័យស្រូវអង្ករនេះ ក្នុងគោលបំណងដើម្បីជួយជំរុញផលិតកម្មស្រូវអង្ករ និងការនាំចេញស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

Click here for English Version : Meeting to review and evaluate rice harvest and export rice


## សហព័ន្ធស្រូវអង្ករកម្ពុជា (Cambodia Rice Federation)

**ប្រធានក្រុមប្រឹក្សាភិបាល (Chairman)**
*លោកឧកញ៉ា ហ៊ុន ឡាក់ (Oknha Hun Lak)*

**ប្រធានសហព័ន្ធ (President)**
*លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)*

**អគ្គលេខាធិការ (Secretary General)**
*លោក លន់ យ៉េង (Mr. Lun Yeng)*

**រៀបរៀង និងចងក្រងដោយ (Compiled by)**
*កញ្ញា សន ឆវីតេ - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*(Ms. Sorn Chhorvyvatey - Communication Coordinator)*

**កែសម្រួលដោយ (Edited by)**
*- លោក ខេ ឡុងម៉េង - មន្ត្រីសម្របសម្រួលគណៈកម្មាធិការប្រតិបត្តិ ស.អ.ក និងការងារប្រចាំតំបន់១&២ (Mr. Khe Longmeng - Executive Committees Coordinator and Zone 1&2 Coordinator)*
*- កញ្ញា ធុន ស្រីមុំ - ប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ*
*(Ms. Thun Sreymom - Admin and Finance Manager)*

**រចនាដោយ (Designed by)**
*កញ្ញា សន ឆវីតេ - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*(Ms. Sorn Chhorvyvatey - Communication Coordinator)*


## តម្លៃស្រូវ និងតម្លៃអង្ករនាំចេញ
## (Paddy price & FOB Price)


សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

តម្លៃអង្ករនាំចេញ FOB Price
as of 31 August 2020

| Rice Varieties | Rice Standard (Price USD/ MT) 5% | 10% | 15% |
|---|---|---|---|
| Jasmine Rice (Malys Angkor) | 900 | | |
| Standard Fragrant Rice_SKO | 785 | | |
| White Rice_Premium (Soft cooking) | 600 | | |
| Parboiled Rice | 570 | | |
| Organic Parboiled Rice (Premium Quality) | 1000 | | |
| Organic White Rice (Premium Quality) | | | 950 |
| Organic Jasmine (Malys Angkor) | 1400 | | |
| Organic Brown Jasmine (Premium Quality) | | 1370 | |

**Source** : Cambodian Exporters and Millers
**Note:** Price Fluctuation : +/- 2%


សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

តម្លៃស្រូវសើម នៅតាមទីតាំង
ដែលកំពុងប្រមូលផល តាមបណ្តាខេត្តមួយចំនួន
ថ្ងៃចន្ទ ទី៣១ ខែសីហា ឆ្នាំ២០២០

| ខេត្ត | ស្រុក | ស្រូវសែនក្រអូប | ស្រូវអ៊ីអ៊ែរ | ស្រូវផ្សេងៗ |
|---|---|---|---|---|
| កំពង់ចាម | ជើងព្រៃ[1] | ១២៥០ | ៩៣០ | |
| កំពង់ធំ | ស្ទឹងសែន[2] | | *៩៣០ | |
| | កំពង់ស្វាយ[3] | | *៩២០ | |
| | ស្ទោង[4] | | *៨៨០ | |
| | សន្ទុក | | *៩០០ | |
| សៀមរាប | ពួក[5] | ១០៣០ | *៨៨០ | |
| ព្រះវិហារ | ឆែប | ១២០០ | *៩២០ | |
| បន្ទាយមានជ័យ | ភ្នំស្រុក | ១២០០ | *៩០០ | |
| | ព្រះនេត្រព្រះ | ១២៣០ | *៩៣០ | |
| | មង្គលបុរី | | ** ៩១០ | |
| បាត់ដំបង | ឯកភ្នំ[6] | | | ៩១០ |
| | បវេល | ១២០០ | | |
| | បាណន់ | ១២០០ | | |
| ពោធិសាត់ | បាកាន | ១២០០ | ៨៥០ | |
| កំពង់ឆ្នាំង | រលាប្អៀរ[7] | | ៩០០ | ១០៧០ |

គិតជារៀល/គីឡូក្រាម

**កំណត់សម្គាល់៖**
*ពូជស្រូវអូអឹម ៥៤៥១ ** ពូជស្រូវអូអឹម ៨៥
1. សហគមន៍កសិកម្មទួលព្រះវិហារ ស្រុកជើងព្រៃ ខេត្តកំពង់ចាម (089 412 149) បាននឹងកំពុងបន្តប្រមូលផលស្រូវសែនក្រអូប ប្រមាណ ២៥០ហិកតា និងស្រូវអ៊ីអ៊ែរនៅសល់តិចតួច។ 2. សហគមន៍កសិកម្មអូរកន្ទរមានជ័យ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ (012 214 628) បាននឹងកំពុងប្រមូលផលស្រូវអូអឹម5451 ប្រមាណ ៣០០ហិកតា។ 3. សហគមន៍កសិកម្មឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ (078 576 321) បាននឹងកំពុងប្រមូលផលស្រូវអូអឹមប្រមាណ ២៥០ ហិកតា។ 4. សហគមន៍ស្ទោងពន្លឺពេជ្រ ស្រុកស្ទោង ខេត្តកំពង់ធំ (012 235 944) បាននឹងកំពុងប្រមូលផលស្រូវអូអឹមប្រមាណ ១០០ហិកតា។ 5. សហគមន៍កែវពណ៌សាមគ្គីចម្រើនផល ស្រុកពួក ខេត្តសៀមរាប (012 219 864) បាននឹងកំពុងប្រមូលផលស្រូវអូអឹមប្រមាណ ៣០ ហិកតា និងសែនក្រអូប ៤០ ហិកតា។ 6. សហគមន៍និរន្តចម្រើនផល ស្រុកឯកភ្នំ ខេត្តបាត់ដំបង (092 409 384) បាននឹងកំពុងប្រមូលផលស្រូវផ្ការំដួលប្រមាណ១០០០ ហិកតា។ 7. សហគមន៍ជ័យជម្នះ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង (092 651 689) បាននឹងកំពុងប្រមូលផលស្រូវផ្កាក្រវាន់ ៥០០តោន។

**អ្នកស្រង់ទិន្នន័យ៖**
លោក ទិតសុទ្ធិ នីយ៉ាណូរីន មន្ត្រីសម្របសម្រួលការងារប្រចាំតំបន់៤និង៥ នៃលេខាធិការដ្ឋានស.អ.ក


(855) 23 559 8999
info@crf.org.kh
Soma Tower, 7th Floor
#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia


https://www.facebook.com/cambodiaricefederation/
www.crf.org.kh
https://twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation